ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ថៃ លើកទី៣ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ

ដោយទទួលបានគោលការណ៍អនុញ្ញាតពី រាជរដ្ឋាភិបាល **ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** បានដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ថៃ លើកទី៣ ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-១៨ ខែកក្កដា ឆ្នាំ២០២៤ នៅទីក្រុងបាងកក ប្រទេសថៃ។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងស្របតាមស្មារតីនៃអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ ដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០១៤ និងឆ្លើយតបទៅនឹងស្មារតីនៃជំនួបទ្វេភាគីរវាង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តម សេដ្ឋា ថាវីស៊ីន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ** កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ ពាក់ព័ន្ធការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍នៃប្រទេសទាំងពីរ។ កិច្ចប្រជុំនេះបានប្រព្រឹត្តទៅក្រោមការដឹកនាំរបស់សហប្រធានទាំងពីរគឺ **ឯកឧត្តម សុខ សូកេន រដ្ឋមន្ត្រីក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា** និង **ឯកឧត្តម Sermsak Pongpanit រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងកីឡានៃព្រះរាជាណាចក្រថៃ** ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB) និង អាជ្ញាធរទេសចរណ៍ថៃ (TAT) ព្រមទាំងវិស័យឯកជនពាក់ព័ន្ធនានា។

អង្គប្រជុំបានស្តាប់របាយការណ៍លទ្ធផលនៃកិច្ចប្រជុំក្រុមការងាររួមគ្នាស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ទ្វេភាគីរវាងកម្ពុជានិងថៃលើកទី៧ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ និងពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម ស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍កម្ពុជា-ថៃ ២០២៣-២០២៥ ព្រមទាំងបានកែសម្រួលចំណុចមួយចំនួននៃផែនការសកម្មភាពរួមគ្នានេះ ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ដោយផ្តោតលើកិច្ចសហប្រតិបត្តិការសំខាន់ៗ ចំនួន០៥ រួមមាន៖

១) ការសម្រួលការធ្វើដំណើរ និងឆ្លងកាត់ព្រំដែន ដោយភាគីទាំងពីរបានឯកភាពពង្រឹងការសម្របសម្រួលការធ្វើដំណើរឆ្លងកាត់ព្រំដែនជូនទេសចរនៃប្រទេសទាំងពីរ និងទេសចរមកពីប្រទេសទីបី។

២) យុទ្ធនាការផ្សព្វផ្សាយទីផ្សារទេសចរណ៍រួមគ្នា "ព្រះរាជាណាចក្រពីរ គោលដៅមួយ" ដោយភាគីទាំងពីរបានពិភាក្សាលើការផ្សព្វផ្សាយរួមគ្នា ការរៀបចំដំណើរទស្សនកិច្ចស្វែងយល់ពីគោលដៅទេសចរណ៍ (Familiarization Trip) ការរៀបចំព្រឹត្តិការណ៍ទេសចរណ៍រួមគ្នា និងការជំរុញការចូលរួមក្នុងព្រឹត្តិការណ៍ទេសចរណ៍ដែលរៀបចំដោយប្រទេសនីមួយៗ។

៣)   ការអភិវឌ្ឍធនធានមនុស្សតាមរយៈការជំរុញការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់អ្នកជំនាញទេសចរណ៍អាស៊ាន (MRA-TP) និងការបម្លាស់ទីអ្នកជំនាញទេសចរណ៍អាស៊ាន ខណៈដែលប្រទេសទាំងពីរជាប្រទេសឆ្នើមក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ។

៤) ការជំរុញអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព ដោយភាគីទាំងពីរបានឯកភាពគ្នាបន្តជំរុញអនុវត្តស្តង់ដាសម្រាប់សេវាកម្មទេសចរណ៍នានា។

៥) ការជំរុញការវិនិយោគក្នុងវិស័យទេសចរណ៍ ដោយភាគីទាំងពីរបានឯកភាពគ្នាបន្តពង្រឹងការចែករំលែកព័ត៌មាន និងសក្តានុពលវិនិយោគក្នុងវិស័យទេសចរណ៍រវាងប្រទេសទាំងពីរ។

លើសពីនេះទៀត ភាគីកម្ពុជានិងភាគីថៃក៏បានសហការរៀបចំសិក្ខាសាលាស្តីពី "កញ្ចប់វិជ្ជាជីវៈទេសចរណ៍រួមគ្នា" រវាងប្រទេសថៃ និងកម្ពុជា ដែលមានការចូលរួមពីវិស័យឯកជនពាក់ព័ន្ធ។

ទន្ទឹមនឹងនេះ កាលពីរសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤ **លោក អ៊ិត វិជិត** នាយកប្រតិបត្តិក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB) បានដឹកនាំក្រុមការងារជួបពិភាក្សាជាមួយអាជ្ញាធរទេសចរណ៍ថៃ (TAT) ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍រវាងស្ថាប័នទាំងពីរ។

ជារួម កិច្ចប្រជុំទ្វេភាគីថ្នាក់រដ្ឋមន្ត្រីទេសចរណ៍កម្ពុជា-ថៃ លើកទី៣នេះ បានប្រព្រឹត្តទៅប្រកបដោយភាពជោគជ័យ ជាមួយនឹងលទ្ធផលប្រកបដោយផ្លែផ្កាក្នុងស្មារតីមិត្តភាព និងសាមគ្គីភាព។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ទីក្រុងបាងកក, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

KINGDOM OF CAMBODIA

NATION RELIGION KING

MINISTRY OF TOURISM

**Press Release**

**The Outcomes of the 3rd Ministerial Meeting on Tourism Cooperation Between Cambodia and Thailand**

**Bangkok, Kingdom of Thailand**

========

With permission from the Royal Government of Cambodia, **H.E. Sok Soken**, Minister of Tourism of Cambodia, led a delegation consisted of leaders and officials of the Ministry of Tourism to the 3rd Ministerial Meeting on Tourism Cooperation between Cambodia and Thailand, which was held from 17-18 July 2024 in Bangkok, Thailand. This meeting was organized in accordance with the Memorandum of Understanding on Cambodia-Thailand Cooperation signed in 2014 and the bilateral meeting between **Samdech Moha Borvor Thipadei HUN MANET, Prime Minister of Cambodia**, and **His Excellency Setha Thavisin, Prime Minister of the Kingdom of Thailand**, on February 7, 2024, during the Official Visit of the Prime Minister of Cambodia to Thailand regarding the promotion of tourism between the two countries. The meeting was chaired by the two Co-Chairs, **H.E. Sok Soken**, Minister of Tourism of the Kingdom of Cambodia, and **H.E. Sermsak Pongpanit**, Minister of Tourism and Sports of the Kingdom of Thailand, with the participation of the Cambodia Tourism Marketing and Promotional Broad (CTB) and the Tourism Authority of Thailand (TAT) as well as relevant private sectors.

The meeting reviewed the results of the 7th Joint Working Group on Bilateral Tourism Cooperation between Cambodia and Thailand held on July 17, 2024 and the progress of the implementation of the Joint Action Plan on Cambodia-Thailand Tourism Cooperation 2023-2025, and revised some points of this joint action plan to respond to the current situation. The meeting focused on five key collaborations:

1. **Enhanced Cross-Border Facilitation:** Both parties agreed to further facilitate cross-border travel for tourists from both nations and tourists from third countries.
2. **"Two Countries, One Destination" Campaign:** The Meeting discussed about joint promotion, familiarization trips, joint tourism events, and participation in each other's tourism events.
3. **Human Resource Development:** Both parties agreed to promote the implementation of the ASEAN Mutual Recognition on Tourism Professionals (MRA-TP) and mobility among ASEAN tourism professionals.
4. **Promoting Quality Tourism:** Both parties agreed to further their collaboration on implementing tourism service standards.

5. **Promoting Tourism Investment:** Both parties committed to enhancing their information sharing and exploring potential investment opportunities between the two countries.

Moreover, both parties jointly organized a Workshop on "Joint Tourism Professional Package" between Thailand and Cambodia, which was participated by relevant private sectors.

Furthermore, on 17 July 2024, **Mr. Ith Vichit,** Executive Director of the Cambodia Tourism Marketing and Promotion Board (CTB), met with representatives of the Tourism Authority of Thailand (TAT) to discuss future collaboration and enhance tourist flows between the two countries.

Overall, the 3rd Ministerial Meeting on Tourism Cooperation between Cambodia and Thailand was a success, with strong collaboration and positive outcomes. END.

Bangkok, 18 July 2024